ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៧៩
ចុះថ្ងៃទី០៣-៥-២០១១
សាលដីកា
លេខ: ៨៨ ក្រ៥.ប
ចុះថ្ងៃទី ០៥-៧-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៧-៦-២០១៣ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៣៧៩ ចុះថ្ងៃទី ០៣-៥-២០១១ រវាង:

- ជនជាប់ចោទ:

១- ឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ ភេទប្រុស អាយុ៣៨ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅ [redacted] ទីលំនៅសព្វថ្ងៃផ្ទះ [redacted] ប្រពន្ធឈ្មោះ [redacted] (រ) មានកូនពីរនាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ជានីតិជន (ក្រៅឃុំ) ។

២- ឈ្មោះ [redacted] រុន អាយុ២៧ឆ្នាំ ជនជាតិខ្មែរ របរធ្វើស្រែ ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅបច្ចុប្បន្ន [redacted] ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ជានីតិជន ។

ចាប់ខ្លួនពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១០ តាមដីកាបង្គាប់អោយឃុំខ្លួនលេខ ៥៨៣ តព្រ ចុះថ្ងៃទី១៨ ខែកក្កដា ២០១០ ។

- លោក [redacted] ម៉ាច មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

- ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍មកនេះ ព្រោះមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោម ។ ខ្លួនមិនមែនជាអ្នករៀបចំគំរោងទេ ខ្លួនស្គាល់តែឈ្មោះ [redacted] សាវុធ ប៉ុណ្ណោះ គឺទើបនឹងស្គាល់បានជាងមួយឆ្នាំប៉ុណ្ណោះ ឯឈ្មោះ [redacted]រុន និងឈ្មោះ [redacted] រិទ្ធ នោះខ្លួនមិនស្គាល់ទេ ។ កាំភ្លើង គឺជារបស់ឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ មិនមែនរបស់ខ្លួនទេ ។ ពេលប្លន់នោះខ្លួនមិនដឹងទេ ខ្លួនបានលុយ ៣០០ ពាន់រៀល ប៉ុន្តែលុយនេះ គឺគាត់សងលុយខ្លួនទេ ខ្លួនបានដឹង ប៉ុន្តែមិនបានប្រព្រឹត្តទេ ។ ការដឹងអំពីការប្រព្រឹត្តរបស់ឈ្មោះ [redacted] រិទ្ធ, [redacted]រុន, [redacted] សាវុធ នេះអ្នកប្រព្រឹត្តនិយាយប្រាប់ខ្លួនការទទួលយកលុយចំនួន ៣០០ពាន់រៀលនេះ គឺឈ្មោះ [redacted] សាវុធ យកមកសងខ្លួន ក្រោយពីសងខ្លួនរួចហើយ ហើយខ្លួនសួរថា លុយនេះបានពីណាទើបឈ្មោះ [redacted] សាវុធ ប្រាប់ថា ប្លន់ខ្លួនប្រកែកថា មិនទទួលឈ្មោះ [redacted] សាវុធ ឆ្លើយថា យកទៅមិនឲ្យពាក់ព័ន្ធទេ ចំណែកអាវុធដែលប្រព្រឹត្តបទល្មើសខ្លួនក៏បោះចោលទៅកន្លែងមកខ្លួនមិនដែលកាន់កាំភ្លើងទេ ។

ស.ឆ ព្រះរាជអាជ្ញាសួរជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយថា ក្រោយពេលកើតហេតុប្រហែល ៣ថ្ងៃ ទើបឃើញកាំភ្លើងឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ យកមកផ្ញើខ្លួន ហើយខ្លួនក៏បោះចោលទៅ ។ ខ្លួនទៅយកលុយនៅមុខវត្តតាំងក្រសាំងដោយលុយនេះឈ្មោះ [redacted] សាវុធ ឲ្យ ។ ខ្លួនសំណូមពរ សុំឲ្យបន្ធូរបន្ថយទោសឲ្យខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តទេ ។

## <u>តំណាងមហាអយ្យការសន្និដ្ឋានថា:</u>

យល់ឃើញថា មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទដូចបទចោទប្រកាន់របស់អយ្យការសាលាដំបូង ។ ជនជាប់ចោទព្រមទទួលយកអង្គហេតុនេះហើយ និងសុំបន្ធូរបន្ថយទោសប៉ុណ្ណោះ ។ គួរតម្កល់សាលក្រមរបស់សាលាដំបូងដោយគ្រាន់តែអនុវត្តតាមក្រមព្រហ្មទណ្ឌវិញ។ ទាក់ទិននឹងទណ្ឌកម្មជូនក្រុមប្រឹក្សាពិចារណាតាមច្បាប់ ។

## <u>មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋាន:</u>

- លោក [redacted] ម៉ាច មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា ការដែលកូនក្តីខ្លួនបានទទួលលុយ គឺពីការជំពាក់ទេ ។ ក្រោយពីប្លន់ជនជាប់ចោទ ឈ្មោះ [redacted]រុន, [redacted]រិទ្ធ ពេលប្លន់ចែកលុយគ្នាតែអ្នកប្លន់ទេ ។ សំណូមពរ សុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

រួចឡើងជិះម៉ូតូបក្សពួកឈ្មោះ [redacted] សារុធ ហៅ ម៉ាប់ និង [redacted] រិទ្ធ ហៅ បាក់ ដែលរង់ចាំខាងក្រៅសំដៅទៅវត្តតាំងក្រសាំង ដើម្បីចែកចំណែកប្រាក់ដែលប្លន់បាន ។ ក្រោយពេលធ្វើសកម្មភាពឈ្មោះ [redacted] វណ្ណា បានជិះម៉ូតូហៃហាកទៅចំណុចណាត់ជួប ដើម្បីទទួលយកចំណែកជាមួយបក្សពួក និងយកអាវុធផុនកា៥៤ មួយដើមពីឈ្មោះ [redacted] សារុធ ហៅ ម៉ាប់វិញ ទៅរក្សាទុក និងបានបោះចោល ដើម្បីបំបិទភស្តុតាង ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២២ ក្រ.២ (ឈ) ចុះថ្ងៃទី១៨-០៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:

១- ផ្តន្ទាទោសឈ្មោះ [redacted] សារុធ ហៅ ម៉ាប់ ភេទប្រុស អាយុ៣៨ឆ្នាំ , ឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ ២៦ឆ្នាំ , ឈ្មោះ [redacted] រុន ភេទប្រុស អាយុ ២៧ឆ្នាំ និងឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗ ០៨ ឆ្នាំ (ប្រាំបីឆ្នាំ) ។

ពីបទ: ប្លន់ និងប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ និងសមគំនិតក្នុងអំពើប្លន់ និងប្រើប្រាស់ អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ និងមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឲ្យចាប់-ឃុំខ្លួនឈ្មោះ [redacted] សារុធ ហៅ ម៉ាប់ ភេទប្រុស អាយុ៣៨ឆ្នាំ នៅពន្ធនាគារ ម១ព្រៃស ក្រសួងមហាផ្ទៃ ។ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣- វត្ថុចាប់យក:

- ម៉ូតូមួយគ្រឿង ម៉ាកវីវ៉ា ពណ៌ខ្មៅ មានលេខតួ BE4CC TH 310997 គ្មានស្លាកលេខ, គ្មានក្បាំង, គ្មានកញ្ចក់ , គ្មានកូនសោរ, គ្មានម៉ាញ៉េតូ, លេខម៉ាស៊ីន E44 TH 3100997 ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ តាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិទ្ធ, [redacted] រុន , [redacted] វណ្ណា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារុធ ហៅ ម៉ាប់ ។

- ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០-៣-២០១១ របស់ឈ្មោះ [redacted] រិទ្ធ , [redacted] រុន, [redacted] វណ្ណា នឹងសាលក្រមព្រហ្មទណ្ឌលេខ ២២ ក្រ២(ឈ) ចុះថ្ងៃទី១៨-៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសំរេចសាលក្រមទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១៧-៨-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១១-០១-២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**<u>នាពេលសវនាការ</u>**

- ជនជាប់ចោទឈ្មោះ [redacted] វណ្ណា (វត្តមាន)
- ជនជាប់ចោទឈ្មោះ [redacted] រុន, [redacted] រិទ្ធ (អវត្តមាន)


២៧៤៧

៣- ឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ របររកស៊ីជាកម្មករសំណង់ ទីកន្លែងកំណើតនៅ [redacted] មានទីលំនៅបច្ចុប្បន្ន [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះមិនស្គាល់ ទោសពីមុនគ្មាន ។

ចាប់ខ្លួនពីថ្ងៃទី១២ ខែកក្កដា ២០១០ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៨៥ តព្រ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ។

- ត្រូវចោទពីបទៈ ប្លន់ និងប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៤- ឈ្មោះ [redacted] វណ្ណា ហៅ វែង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរទិញអេតចាយ ទីកន្លែងកំណើត [redacted] មានទីលំនៅ [redacted] នៅលីវ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ជានីតិជន ។

- ត្រូវចោទពីបទៈ សមគំនិតក្នុងអំពើប្លន់និងប្រើប្រាស់អាវុធហាមឃាត់ខុសច្បាប់ ប្រព្រឹត្តនៅភូមិ ត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៤១ឆ្នាំ មុខរបរទិញលក់អេតចាយ ទីកន្លែងកំណើត ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល មានទីលំនៅផ្ទះលេខ ១៤ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

- តាមបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០-៣-២០១១ របស់ឈ្មោះ [redacted] រិទ្ធ , [redacted] រុន, [redacted] វណ្ណា នឹងសាលក្រមព្រហ្មទណ្ឌលេខ ២២ ក្រ២(ឈ) ចុះថ្ងៃទី១៨-៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច សេចក្តីសំរេចសាលក្រមទាំងមូល ។

<u>៦រឿងហេតុមានដូចតទៅ:</u>

ក្នុងការធ្វើសកម្មភាពឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ ,ឈ្មោះ [redacted] ផុង ,ឈ្មោះ [redacted] រុន និង [redacted] រិទ្ធ បានរៀបចំផែនការប្លន់ជនរងគ្រោះឈ្មោះ [redacted] ចក្កា មានទីលំនៅភូមិត្រពាំ [redacted] ដោយមានឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ ជាមេក្លោង និងមានឈ្មោះ [redacted] វណ្ណា ជាអ្នកផ្តល់អាវុធកា៥៤ ដើម្បីធ្វើសកម្មភាព លុះដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ ,ឈ្មោះ [redacted] ផុង ,ឈ្មោះ [redacted] រុន បានគាស់ជំបូលផ្ទះរបស់ជនរងគ្រោះចូលសំងំលាក់ខ្លួនរហូតដល់ម៉ោង ៩ព្រឹក ពេលជនរងគ្រោះចូលដល់ក្នុងផ្ទះ ឈ្មោះ [redacted] ផុង បានយកអាវុធភ្ជង់ចំសៀតផ្កាជនរងគ្រោះ ហើយឈ្មោះ [redacted] រុន ជាអ្នកចងដៃចងជើង និងយកក្រមាមកចងមាត់ជនរងគ្រោះប្លន់យកប្រាក់ ២២.០០០.០០០រៀល (ម្ភៃពីរលានរៀល) ទូរសព្ទ០២គ្រឿង ហើយនាំគ្នាគេចខ្លួនដោយជិះម៉ូតូជនរងគ្រោះយកទៅទុកចោល

## សាលាឧទ្ធរណ៍យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ២៣៦ ចុះថ្ងៃទី៣០-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា, បណ្តឹងឧទ្ធរណ៍លេខ ២៣៧ ចុះថ្ងៃទី៣០-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] រុន និងបណ្តឹងឧទ្ធរណ៍លេខ ២៣៨ ចុះថ្ងៃទី៣០-៣-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ ទាំង ៣នាក់នោះប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចទាំងមូលនៃសាលក្រមព្រហ្មទណ្ឌលេខ ២២(ឈ) ចុះថ្ងៃទី១៨-៣-២០១១ បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចជំនុំជម្រះបាន ។

២- តាមអង្គហេតុករណីប្លន់ជនរងគ្រោះឈ្មោះ [redacted] ចក្កា ភេទប្រុស អាយុ៤១ឆ្នាំ មុខរបរទិញ លក់ អេតចាយនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវក្រុមចោរមួយក្រុមបានគាស់ដំបូលផ្ទះ ចូលសំងំលាក់ខ្លួន ហើយបានដកកាំភ្លើងភ្ជង់ប្លន់បានសម្រេចនូវប្រាក់ ២២លានរៀល រួមទាំងទូរស័ព្ទម៉ាក Nokia ចំនួន ០២គ្រឿង ប្រព្រឹត្តនៅភូមិត្រពាំងក្រសាំង ឃុំត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២២-៦-២០១០ ត្រូវបានសមត្ថកិច្ចនគរបាលយុត្តិធម៌ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] រុន, [redacted] រិទ្ធ និង អ៊ុក វណ្ណា ថ្ងៃទី១៤-៧-២០១០ ដោយសង្ស័យថា មានការពាក់ព័ន្ធនឹងអំពើល្មើសខាងលើ ។

៣- តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់, [redacted] រិទ្ធិ និង [redacted] រុន មានលក្ខណៈប្រហាក់ប្រហែលគ្នាថា ពួកគេពិតជាបានរៀបចំផែនការប្លន់តាលក់អេតចាយប្រាកដមែន ដោយឈ្មោះ [redacted] រិទ្ធ ជាអ្នកមើលផ្លូវ ឈ្មោះ [redacted] រុន ជាអ្នកបើកដំបូល ហើយចងដៃជនរងគ្រោះ រីឯឈ្មោះ [redacted] វណ្ណា ហៅ វែង ជាអ្នកផ្តល់អាវុធ ហើយផលដែលបានមកពីការប្រព្រឹត្តនេះពួកគេយកមកចែកគ្នាតាមចំណែករៀងៗខ្លួន ដោយឡែកជនជាប់ចោទឈ្មោះ [redacted] វណ្ណា ពុំបានចូលរួមធ្វើសកម្មភាពនៅថ្ងៃកើតហេតុនោះទេ ឈ្មោះនេះគ្រាន់តែឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ ហៅទៅទទួលប្រាក់ជំពាក់ខ្លួនប៉ុណ្ណោះ ក្រោយពីបានទទួលប្រាក់ហើយ ជនជាប់ចោទឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ បានប្រគល់អាវុធឲ្យឈ្មោះ [redacted] វណ្ណា ទុកដោយមានការភ័យខ្លាចក៏បោះចោលនៅកន្លែងល្ង ដូចនេះការដាក់ឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណា ឲ្យទទួលខុសត្រូវក្នុងបទចោទប្រកាន់ពីបទ សមគំនិតក្នុងអំពើប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២-៦-២០១០ តាមមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌនោះមិនត្រឹមត្រូវតាមអង្គហេតុ និងអំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ វែង ឡើយ ។

៤- តាមអង្គហេតុ និងពេលសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានសារភាពទទួលស្គាល់ប្រាក់ចំនួន ៣លានរៀល ពីជនជាប់ចោទឈ្មោះ [redacted] សាវុធ ហៅ ម៉ាប់ ប្រាកដមែន ដូចនេះជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ វែង គួរប្រែសាលាឧទ្ធរណ៍ដាក់ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវក្នុងបទចោទប្រកាន់ ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២-៦-២០១០ តាមបញ្ញត្តិមាត្រា ៤០០ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ។

៥- មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ឲ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារុធ, [redacted] រុន និង [redacted] រិទ្ធិ ពិតជាបានធ្វើសកម្មភាពប្រព្រឹត្តបទល្មើសទៅលើជនរងគ្រោះដូចបទចោទប្រកាន់របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ, មាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន ។

៦- រឿងក្តីព្រហ្មទណ្ឌនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេតលើកយកភស្តុតាងមកសំអាងសព្វគ្រប់ហើយ សាលាឧទ្ធរណ៍មិនលើកសំអាងហេតុដដែលមកបញ្ជាក់ជូនជាថ្មីទៀតទេ ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ២២ ក្រ២ (ឈ) ចុះថ្ងៃទី១៨-៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមកមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការលើកលែងតែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ វែង គួរលើកមកពិចារណាជាថ្មីតាមការយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## ឧនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០-៣-២០១១ របស់ឈ្មោះ [redacted] រិទ្ធិ និងឈ្មោះ [redacted] រុន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២- ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ វែង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ វែង ពីបទសមគំនិតក្នុងអំពើប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ មកជាបទ ទទួលផលចោរកម្ម តាមមាត្រា ៤០០ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ វិញ ។

៤- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២ ក្រ២(ឈ) ចុះថ្ងៃទី១៨-៣-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] វណ្ណា ហៅ វែង ត្រូវកែប្រែពីដាក់ពន្ធនាគារ ៨ឆ្នាំ មកជា ដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ វិញ ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិត្រពាំងក្រសាំង សង្កាត់ត្រពាំងក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២២-៦-២០១០ តាមបញ្ញត្តិមាត្រា ៤០០ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ក្រៅពីនេះរក្សាទុកដដែល ។

៥- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៦- សាលដីកានេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៧-៦-២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រិទ្ធិ និងឈ្មោះ [redacted] រុន ប្រកាសជាសាធារណៈ ថ្ងៃទី០៥-៧-២០១៣ ។

- បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះបានចូលជាស្ថាពរ និងមានអានុភាពអនុវត្តទៅលើឈ្មោះ [redacted] រុន និង [redacted] វណ្ណា តែប៉ុណ្ណោះ ក្រៅពីនេះពុំមានអានុភាពទេ ។

២៦០

សេចក្តីនេះ៖ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី............ ខែ............ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

[redacted]

២៦១